# កិច្ចសម្ភសរបស់អ៊ីឈ្មោះ ទូច ច្រឹប

កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ ទូច ច្រឹប

កៈ ចាសអ៊ី…ជាដំបូងជំរាបសួរអ៊ី!

ខៈ អឹម!

កៈ ចាសអ៊ី! ថ្ងៃនេះខ្ញុំមានឪកាលដើម្បីមកសម្ភាសអ៊ីផ្ទាល់ ហើយខ្ញុំឈ្មោះ ហេង សុជីវី ខ្ញុំធ្វើការស្ម័គ្រចិត្តនៅក្នុងគំរោងរបស់ខាងសាលា BYU នៅខាងសហរដ្ឋអាមេរិចហើយគំរោងរបស់ខាងសាលាមួយនិងគេចង់ជួយចងក្រងពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងទៅអំពីពង្សប្រវត្តិរបស់គាត់និងក្រុមគ្រួសាររបស់គាត់នឹងជីវិតពិតបទពិសោធន៍របស់គាត់តាំងពីមុនរហូតមកដល់ឥឡូវគាត់បានឆ្លងកាត់អីគេខ្លះ ដើម្បីអោយគេចែកចាយទៅអោយកូនចៅជំនាន់ក្រោយគេបានស្គាល់ដែរ ជាពិសេសកូនចៅរបស់អ៊ីផ្ទាល់តែម្តងដែលគាត់ចង់ដឹងអំពីរពង្សប្រវត្តិរបស់ម្តាយឪពុករបស់គាត់និង គាត់អាចនិងចូលទៅក្នុង Website របស់ខាងសាលាបានអញ្ចឹងណាស់អ៊ី!

ខៈ ចាស!

កៈ ចាស! អញ្ចឹងអ៊ីថ្ងៃនេះ តើអ៊ីអនុញ្ញាតអោយខ្ញុំធ្វើការថតរូបរបស់អ៊ី ហើយនិងយកសំលេងរបស់អ៊ីយកទៅផុសនៅក្នុយ Website របស់ខាងសាលាដែលឬទេ?

ខៈ ចាស! ចាស! បានអូន!

កៈ ចាសអរគុណអ៊ី! អញ្ចឹងជាដំបូងនៃការសម្ភាសថ្ងៃនិងជាថ្ងៃទី២៣ ខែ០៧ ឆ្នាំ ២០១៨ ហើយអ៊ី…អ៊ីមានឈ្មោះអ្វីដែរអ៊ី?

ខៈ ខ្ញុំមានឈ្មោះ ច្រឹប អូន!

កៈ ចាស?

ខៈ ខ្ញុំមានឈ្មោះច្រឹប!

កៈ ហើយអ៊ី…ឈ្មោះនិងត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណអត់អ៊ី?

ខ៖ ខ្ញុំអត់មានអត្តសញ្ញាណប័ណ្ណផងខ្ញុំបានបាត់ហើយ បាត់អត្តសញ្ញាណប័ណ្ណបាត់ហើយ!

ក៖ ចាស! តែឈ្មោះរបស់អ៊ីនិងត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណត្រូវជាមួយនិងនាមត្រូវអស់ហើយហ៎អ៊ី?

ខ៖ ចាស! ចាស! ត្រូវគ្នាទាំងអស់!

ក៖ អ៊ីមានឈ្មោះហៅក្រៅដែរឬទេ?

ខ៖ ហ្នឹងហើយខ្ញុំមានឈ្មោះនិងឈ្មោះច្រឹបនិងគេហៅក្រៅហើយ!

ក៖ ចុះយ៉ាងម៉េចបានជាគែដាក់ឈ្មោះអោយអ៊ីអញ្ចឹងវិញ?

ខ៖ ឈ្មោះខ្ញុំនិងកាលពីតូចមកអញ្ចឹង គឺឪពុកម្តាយគាត់ជាអ្នកដាក់ឈ្មោះអោយអញ្ចឹងតែម្តង!

ក៖ ចាស! ចុះគាត់អត់មានប្រាប់ថាឈ្មោះនិងមានអត្តន័យយ៉ាងដូចម្តេចដែរអ៊ីឈ្មោះនិង?

ខ៖ ម៉ែរបស់ខ្ញុំគាត់ដាក់ឈ្មោះច្រឹបនិងអោយតែម្តងដាក់ឈ្មោះហ្នឹងតាំពីតូចមក!

ក៖ គាត់ដាក់ឈ្មោះអញ្ចឹងមកតែម្តង ដាក់ឈ្មោះតាំងពីតូចតាំងពីអីនឹងមកតែម្តងហ៎អ៊ី?

ខ៖ ចាស! គាត់ដាក់ឈ្មោះហ្នឹងអោយខ្ញុំតាំងពីតូចមកតែម្តង!

ក៖ ហើយគាត់មានដែលប្រាប់អ៊ីទេថាឈ្មោះនិងមានអត្តន័យយ៉ាងម៉េចទេហ៎អ៊ី?

ខ៖ គាត់ដាក់ឈ្មោះអញ្ចឹងអោយតែម្តងឈ្មោះរបស់ឪពុកខ្ញុំគាត់មានឈ្មោះ ទូច!

ក៖ ចាស! ហើយអ៊ី...អ៊ីមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំមានអាយុ៣៨ឆ្នាំហើយ!

ក៖ អ៊ីកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ ខ្ញុំកើតចិតសិបប្រាំបួន(ឆ្នាំ១៩៧៩) កើតឆ្នាំចិតសិបប្រាំបួនអញ្ចឹងហើយ កើតឆ្នាំចិតសិបប្រាំបួនអីហ្នឹង!

ក៖ ចាស! ចុះឆ្នាំវិញអ៊ីដូចជាឆ្នាំចន្ទគតិអីនឹងអ៊ីកើយនៅក្នុងឆ្នាំសត្វណាដែរ?

ខ៖ ចាស! ខ្ញុំកើតនៅក្នុងឆ្នាំវក!

ក៖ អ៊ីកើតនៅកើតនៅក្នុងកន្លែងណាដែរទីតាំង?

ខ៖ ខ្ញុំកើតនៅក្នុងខេត្តកណ្ដាលកើតនៅរកាកោងយើងនិង កើតនៅរកាកោងនិង!

ក៖ អ៎....ស្ថិតនៅភូមិឃុំអីគេអ៊ី?

ខ៖ ខ្ញុំនៅភូមិឃុំស្រុកមុខកំពូលខេត្តកណ្ដាល កើតនៅស្រុកមុខកំពូលខេត្តកណ្ដាលរកាកោងហ្នឹង!

ក៖ ចាស! ចុះសមាជិកក្រុមគ្រួសាររបស់អ៊ី អ៊ីមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូនពីរនាក់ស្រីមួយប្រុស...ស្រីៗទាំងពីរនឹងបងប្អូនរបស់ខ្ញុំ!

ក៖ ចាស! អ៊ីជាកូនទីប៉ុន្មាន?

ខ៖ ខ្ញុំជាកូនទីមួយ!

ក៖ អឺ...បងប្អូនរបស់អ៊ីគាត់មានឈ្មោះអីគេខ្លះ?

ខ៖ បងប្អូនរបស់ខ្ញុំគាត់មានឈ្មោះ ច្រែង!

ក៖ ចាស! គាត់មានឈ្មោះអ្វីដែរអ៊ីសុំឈ្មោះម្ដងទៀតស្ដាប់មិនបានអំបាញ់មិញ!

ខ៖ ប្អូនរបស់ខ្ញុំគាត់មានឈ្មោះ ទូច ច្រែង ខ្ញុំវិញមានឈ្មោះ ទូច ច្រឹប!

ក៖ ចាស! ហើយអ៊ីមានតែពីរនាក់បងប្អូនហ្នឹងទេ!

ខ៖ អឺម....ចាស!

ក៖ អ៊ីមានការចងចាំអីខ្លះពីប្អូនរបស់អ៊ីកាលនឹងកាលនៅវ័យក្មេង?

ខ៖ ប្អូនរបស់ខ្ញុំអត់មានបានចងចាំអីទេពីព្រោះឥឡូវនិងវាឈប់រៀនរៀបការហើយបានប្ដីបានកូនហើយនិង មានប្ដីមានកូនហើយ!

ក៖ អ៎...គាត់ធ្វើការអីដែលអ៊ី?

ខ៖ ប្អូនរបស់ខ្ញុំនឹងនៅធ្វើការតែឥឡូវនិងគាត់ពោះធំហើយ ប្ដីគាត់នៅធ្វើការ!

ក៖ ចាស!

ខ៖
ខ្ញុំហ្នឹងដើររើសអេតចាយនិងដៃររទេះមួយនិងរបស់ប្តីរបស់បងនិងខ្លួនឯងនិងអត់មានរទេះទេ!

ក៖ អញ្ជឹងកាលអ៊ីនៅពីក្មេងអ៊ីមានការចងចាំអីគេខ្លះដែលទាក់ទងជាមួយនិងបងប្អូនរបស់អ៊ី?

ខ៖
មានភាពធម្មតាហ្នឹងជាមួយបងប្អូនអីនឹងតែឥឡូវនិងខ្ញុំអត់មានម្តាយទេម្តាយរបស់ខ្ញុំគាត់ខូច (ស្លាប់) បាត់ហើយគាត់ខូច (ស្លាប់) ហើយម្តាយរបស់ខ្ញុំ!

ក៖
ប៉ុន្តែកាលពេលអ៊ីនៅពីក្មេងៗដូចថាអ៊ីអឺ...តែងតែធ្វើអ្វីខ្លះនិងលេងអ្វីខ្លះជាមួយបងប្អូនរបស់អ៊ី?

ខ៖ អត់ៗមានធ្វើអីទេគ្រាន់តែបានដើរលេងជាមួយបងប្អូនធម្មតាអញ្ជឹងទៅដើរលេងជាមួយគ្នាធម្មតាៗនិង!

ក៖ អ់...ចាស! ហើយទាក់ទងជាមួយនឹងអ...អ៊ីវិញគ្រាន់តែរើសអេតចាយតែមួយមុខនិងទេហ៎?

ខ៖ ខ្ញុំរើសអេតចាយតែមួយមុខហ្នឹងទេ!

ក៖ អ៊ីមានធ្វើការងារផ្សេងទេអ៊ី?

ខ៖ អត់ទេ!

ក៖ អ៊ីអត់មានធ្វើការងារអ្វីផ្សេងក្រៅពីរការងារមួយនិងដើម្បីចិញ្ចឹងជីវិតខ្លួនឯង?

ខ៖ ចាស! អត់មានធ្វើការងារអីផ្សេងផងក្រៅតែពីការងាររើសអេតចាយហ្នឹង!

ក៖ រយះពេលប៉ុន្មានឆ្នាំហើយដែលអ៊ីប្រកបមុខរបរមួយហ្នឹង?

ខ៖ ខ្ញុំប្រាំបួនឆ្នាំមកហើយ យូហើយខ្ញុំធ្វើអស់រយះពេលប្រាំបួនឆ្នាំហើយហ្នឹង!

ក៖ អ៊ីហើយចុះឪពុកម្តាយរបស់អ៊ីពួកគាត់មានឈ្មោះអ្វីដែរ?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានឈ្មោះ ថុល ឪពុករបស់ខ្ញុំគាត់ឈ្មោះ ទូច!

ក៖ ចាស! ចុះគាត់អាយុប៉ុន្មានហើយឆ្នាំហ្នឹង?

ខ៖ ម៉ែខ្ញុំគាត់ខូចយូរហើយ (ស្លាប់) គាត់ខូចតាំងតែពីគាត់មានអាយុហុកសិបប្រាំពីរឆ្នាំមកម្លេះតែឥឡូវនិងគាត់មានអាយុហុកសិប

ប្រាំបួនឆ្នាំហើយគាត់ខូច (ស្លាប់) បាត់ហើយ ឪពុករបស់ខ្ញុំគាត់ខូច (ស្លាប់) តាំងពីគាត់ធ្វើទាហ៊ានតាំងពីខ្ញុំនៅតូចៗគាត់ទៅធ្វើការនៅស្រុកគេទៅដល់ពេលនឹងគាត់បានផ្ទុះមីនខូច(ស្លាប់)ទៅ!

កៈ អូ..នៅគាត់ស្លាប់នៅស្រុកណាដែរ?

ខៈ
គាត់ជិះឡានពីយើងទៅនិងជិះឡានអស់បីយប់បីថ្ងៃនោះបានដល់នៅឆ្ងាយណាស់ហើយទៅគាត់ធ្វើជាមេគេ
គាត់ធ្វើជាមេរបស់គេពេលសំរាកគាត់ទៅគាត់ចងអង្រឹងដេកដល់តែពេលធ្លាក់ពីលើអង្រឹងនិងទៅផ្ទុះគ្រាប់បែកគេនិងក៏ខូច (ស្លាប់) ទៅ!

កៈ អឹម...អ៊ីបានឃើញទាន់និងភ្នែកឬក៏គេជាអ្នកប្រាប់?

ខៈ អត់ទេខ្ញុំអត់ដឹងផងកាលនឹងខ្ញុំនៅតូចៗ!

កៈ គាត់នៅស្រុកគេនិងនៅស្រុកថៃទេដឹង នៅថៃ?

ខៈ នៅស្រុកខ្មែរយើងនិងទេក៏ប៉ុន្តែគាត់នៅឆ្ងាយណាស់!

កៈ អ៎...នៅតាមជិតព្រំដែនអញ្ចឹងទៅ!

ខៈ ចាស! គេផ្លាស់គាត់អោយទៅនិងដល់ពេលអញ្ចឹងទៅគាត់ធ្លាក់ទៅក៏ត្រូវផ្ទុះគ្រាប់ទៅ!

កៈ ចុះអ៊ីមានចាំថ្ងៃខែឆ្នាំកំណើតរបស់ពួកគាត់ដែលកើតទេ?

ខៈ ខ្ញុំអត់បានចាំផងថ្ងៃកំណើតរបស់គាត់ខ្ញុំអត់មានបានចាំផង!

កៈ ចុះឆ្នាំសត្វវិញ តើគាតកើតនៅក្នុងឆ្នាំណាដែរ?

ខៈ
ឪពុករបស់ខ្ញុំប្រសិនបើជាគាត់នៅរស់សព្វថ្ងៃនិងគាត់ប្រហែលជាមានអាយុហុកសិបឆ្នាំជាង(៦០ឆ្នាំ)ហើយ ឪពុករបស់ខ្ញុំនិងព្រោះម្ដាយរបស់ខ្ញុំគាត់មានអាយុហុកសិបឆ្នាំជាងហើយគាត់បងឪពុករបស់ខ្ញុំ!

កៈ ចាស! ចុះអ៊ីៗអត់មានដែលសួរគាត់ថាគាត់កើតនៅក្នុងឆ្នាំណាទេហ៎អ៊ី?

ខៈ អត់បានដឹងផងឪពុករបស់ខ្ញុំ!

កៈ ចុះគាត់កើតនៅកន្លែងណាស្រុកណាដែលអីមានដឹងអត់?

ខៈ គាត់កើតនៅស្រុករបស់គាត់និងគាត់បានកើតនៅជិតរកាកោងដែរតែខាងនៅស្វាយជ្រុំស្រុកស្វាយជ្រុំហើយ...នៅស្វាយជ្រុំដឹងតែថាឪពុកគាត់នៅស្វាយជ្រុំ!

កៈ អ៎...អញ្ចឹង!

ខៈ ចាស! តែគាត់កើតនៅនិងមានឈ្មោះស្វាយជ្រុំនិងតែម្តង!

កៈ អ៎...ចាស! គាត់កើតនៅទីនោះទាំងពីរនាក់តែម្តងហ៎អី?

ខៈ ឪពុកៗរបស់ខ្ញុំហើយនិងម្តាយរបស់ខ្ញុំ គាត់កើតនៅហ្នឹង!

កៈ ចាស! ក៏ប៉ុន្តែអឺ...ទីតាំងកំណើតហ្នឹងកន្លែងដែលគាត់បានកើតនិងគាត់ទាំងពីរនាក់គាត់ហ្នឹងគឺគាត់កើតនៅម្តុំស្វាយជ្រុំហ្នឹងតែម្តង!

ខៈ ចាស! ម៉ែរបស់ខ្ញុំគាត់កើតនៅម្តុំស្វាយជ្រុំហ្នឹងតែម្តង!

កៈ អញ្ចឹងចុះអឺ...អីពេលនិងឪពុករបស់អីគាត់ជាមេគ្រួសារអញ្ចឹងគាត់ជាអ្នកចិញ្ចឹងគ្រួសារឬក៏យ៉ាងម៉េចដែលអី?

ខៈ ឪពុករបស់ខ្ញុំគាត់ជាអ្នករកស៊ីចិញ្ចឹមពួកខ្ញុំមកដល់ពេលដែលគាត់ខូច(ស្លាប់)ទៅគេផ្តាត់របបទៅគេលែងចិញ្ចឹម!

កៈ អូ...ចាស

ខៈ កាលនិងខ្ញុំត្រូវបានអង្ករហូបដល់ពេលគាត់ខូច(ស្លាប់)ទៅគេអត់អោយអង្ករអោយអីទេ!

កៈ អឹម...អញ្ចឹង តើកាលនិងឪពុករបស់អីគាត់ប្រកបមុខរបរធ្វើអ្វីដែលដើម្បីចិញ្ចឹងជីវិត?

ខៈ គាត់ធ្វើជាទាហ៊ានគាត់ធ្វើទាហ៊ានគាត់ធ្វើជាមេរបស់គេណាស់ដល់ពេលអញ្ចឹងទៅគេបានផ្លាស់រគាត់អោយគាត់ទៅឆ្ងាយ!

កៈ អឹម...

ខ៖ ដល់ពេលផ្លាស់គាត់ទៅនិង គាត់ក៏បានផ្ទុះគ្រាប់បែកត្រឹមចង្កេះផ្ទុះអញ្ចឹងទៅគាត់ក៏ខូច(ស្លាប់) ទៅ!

ក៖ ចាស! ចុះគាត់ជាមនុស្សបែបណាដែលអី?

ខ៖ គាត់ៗជាមនុស្សដូចយើងធម្មតាៗនិងដូចយើងអញ្ចឹងក៏ប៉ុន្តែគាត់ជាអ្នកធ្វើការនិងទៅដល់ពេលដែលគេផ្លាស់គាត់អោយទៅគាត់ដល់ទទួលគាត់អញ្ចឹងទៅណាស់គាត់បើគាត់នៅក៏គាត់ជួយកូនដែរ!

ក៖ ចាស! ចុះម្តាយរបស់អ៊ីវិញគាត់...

ខ៖ ម៉ែរបស់ខ្ញុំគាត់ខូច (ស្លាប់) គ្រោះថ្នាក់ចរាចរណ៍ខូចហើយពេលគាត់ចុះពីលើឡានមកដល់ឡាននឹងគេទៅគាត់អត់ទាន់បានឈានជើងចុះស្រួលបួលណាស់ទទូលឡានគេទៅៗបោកក្បាលនៅនឹងថ្នល់យើងនឹងស្លាប់ទៅ!

ក៖ អូ...ចុះគាត់មានជាមនុស្សបែបណាដែលអី?

ខ៖ គាត់ធម្មតានឹងគាត់បានកូនពីរនឹងការបានពីរជាមួយនឹងឪពុកខ្ញុំនឹងគាត់អត់យកប្តីទៀតនឹង!

ក៖ ចុះអ៊ីមានការចេងចាំអ្វីខ្លះដែលទាក់ទងជាមួយនិងឪពុកម្តាយរបស់អ៊ីដែរ?

ខ៖ ប៉ុន្នឹងចងចាំរឿងគាត់ប៉ុន្នឹងប្តីប្រពន្ធគាត់ពេលប្តីរបស់គាត់បានខូច (ស្លាប់) អញ្ចឹងទៅគាត់អត់មានយកប្តីយកអីទៀតទេគាត់នៅតែចាំប្តីរបស់គាត់តែមួយនិង (សំលេងរំខាន)!

ក៖ ចាស! ហើយអឺ...ទាក់ទងជាមួយនិងក្នុងជីវិតរបស់កាលពីនៅពីក្មេងៗអ៊ីមានដែលគាត់មានបានប្រាប់ទេថាគាត់មានមុខរបររកស៊ីអ្វីដែរ?

ខ៖ គាលនិងគាត់នៅលក់ថ្នាំបុរាណ (ស្តាប់មិនបាន ៧:៥៥នាទី) គាត់លក់តាមអីនិងទៅលក់ថ្នាំអញ្ចឹងទៅគាត់ទៅលក់ដល់បាត់ដំបងអីនឹងគាត់លក់ថ្នាំបុរាណចិញ្ចឹមកូន!

ក៖ គាត់ជិះកង់លក់កាលនិងហ៎អី?

ខ៖ អត់ទេគាត់ជិះឡានយើងនោះគេអោយជិះនៅជិតរ៉ារទេះភ្លើងនិងទៅកាលនិងខ្ញុំនៅតូចៗគាត់រកស៊ីចិញ្ចឹមកូន!

ក៖ អញ្ចឹងយូរៗបានគាត់មកលេងផ្ទះមកអីនិងយូរៗបានមកម្តង!

ខ៖ ចាស! ក្នុងមួយខែបានគាត់មកលេងម្តងអញ្ចចឹងទៅ!

ក៖ ចាស! ចុះទាក់ទងជាមួយនិងជីដូនជីតារបស់អីវិញ អីមានចាំឬអត់ថាអំពីលោកយាយលោកតារបស់អី?

ខ៖ លោកយាយរបស់ខ្ញុំគាត់បានខូច (ស្លាប់) ហើយនិងលោកយាយរបស់ខ្ញុំ!

ក៖ លោកយាយរបស់អីគាត់មានឈ្មោះអ្វីដែរ?

ខ៖ លោកយាយរបស់ខ្ញុំគាត់ឈ្មោះលោកយាយ ទូច!

ក៖ គាត់ឈ្មោះលោកយាយទូច គាត់អឺ...ត្រូវជាឪពុកម្តាយខាងអឺ...

ខ៖ លោកយាយរបស់ខ្ញុំបង្កើតខាងម្តាយរបស់ខ្ញុំ!

ក៖ គាត់ជាលោកយាយខាងម្តាយរបស់អី!

ខ៖ ចាស!

ក៖ ចុះខាងលោកឪពុកវិញ?

ខ៖ អឺ...គាត់មានឈ្មោះលោកយាយ អ៊ឹម លោកយាយ អ៊ឹម!

ក៖ ចុះលោកតាខាងម្តាយខាងឪពុករបស់អីវិញ?

ខ៖ ខ្ញុំអត់ស្គាល់គាត់ផងលោកតារបស់ខ្ញុំអត់ស្គាល់ផងនិងយាយរបស់ខ្ញុំឈ្មោះលោកយាយទូច លោកតារបស់ខ្ញុំគាត់មានឈ្មោះ ស៊ិន ចាស!

ក៖ ចាស! ហើយចុះគាត់កើតនៅឆ្នាំណានៅកន្លែងណាដែរ?

ខ៖ គាត់កើតនិងគាត់កើតនៅក្នុងស្រុកនិង នៅស្រុករកាកោងគឺស្រុករបស់គាត់និង!

ក៖ អ៎...

ខ៖ គាត់ខូច(ស្លាប់ )គាត់បានខូច (ស្លាប់)នៅស្រុកគាត់នឹងដែរ!

ក៖ ចុះថ្ងៃខែឆ្នាំកំណើតរបស់គាត់វិញ?

ខ៖ ខ្ញុំអត់បានចាំផងនឹង (ស្តាប់មិនបានច្បាស់ ៩:០៥នាទី)!

ក៖ ចុះអ៊ីធ្លាប់ដឹងអំពីរឿងអីគេខ្លះពីលោកយាយលោកតារបស់អ៊ីទេ?

ខ៖ អត់បានដឹងទេពីព្រោះខ្ញុំអត់បានកើតទាន់គាត់ទេ គាត់ខ្ញុំកើតអត់ទាន់គាត់ទេ!

ក៖ ទាក់ទងជាមួយនិងក្រុមគ្រួសារវិញ អ៊ីសព្វថ្ងៃមានរៀបអាពាហ៍ពិពាហ៍ហើយឬនៅអ៊ី?

ខ៖ ខ្ញុំមានគ្រួសារហើយក៏ប៉ុន្តែខ្ញុំនិងប្តីរបស់ខ្ញុំមានកូនស្រីមួយកូនខ្ញុំមានអាយុ១១ឆ្នាំនិងហើយប្តីរបស់ខ្ញុំគាត់ចែកឋានទៅហើយ!

ក៖ អញ្ចឹង! ស្វាមីរបស់អ៊ីគាត់មានឈ្មោះអ្វីដែរ?

ខ៖ ប្តីរបស់ខ្ញុំគាត់បានខូច(ស្លាប់)ហើយប្តីរបស់ខ្ញុំ!

ក៖ អំ...គាត់ស្លាប់ទៅយូរហើយហ៎អ៊ី?

ខ៖ ចាស! គាត់ស្លាប់ទៅយូរហើយ ខ្ញុំថាទាក់ទងហើយរកការងារធ្វើ កូនរបស់ខ្ញុំធំស្រករមីអូនឯងនិងគិតថារកការងារធ្វើលក់បាយក្នុងហាងគេនឹងណាស់ ឥឡូវនិងកំពុងថារៀបចំរកការងារធ្វើខ្ញុំថារកការងារធ្វើទៅគ្រាន់ជួយម៉ែឈប់ដើររើសអេតចាយទៀតហើយរទេះនេះរបស់បងនឹង ពេលដែលបងសំរាកទៅសុំបងរកទៅណាស់ទៅមួយភ្លែតៗគ្រាន់បានលុយទិញបាយហូបទៅណាស់!

ក៖ ចាស! អូ...ហើយអ៊ីកាលនិងរៀបកាលនៅពេលណាដែលអ៊ីមានចាំទេ?

ខ៖ ខ្ញុំរៀបការៗប្រហែលជាប្រាំមួយប្រាំពីរដណ្តប់ឆ្នាំ (១៦ទៅ១៧ឆ្នាំ) ហើយខ្ញុំការដប់ប្រាំពីរដប់ប្រាំបីឆ្នាំហើយ កូនខ្ញុំឥឡូវនិងមានអាយុ១១ឆ្នាំហើយបើគិតទៅ!

ក៖ អ៊ីរៀបការនៅក្នុងឆ្នាំណាដែរ?

ខ៖ អត់ដឹងឆ្នាំណាផងភ្លេចបាត់ហើយ!

កៈ អ៊ីរៀបអាពាហ៍ពិពាហ៍និងកាលនិងឪពុកម្ដាយជាអ្នករៀបចំអោយឬក៏ស្រលាញ់គ្នា?

ខៈ ស្រលាញ់គ្នាគាត់រៀបចំយើងស្រលាញ់គ្នាទៅក៏គាត់រៀបចំការអោយកូនការជាមួយគ្នាម៉ង!

កៈ ចាស! ពេលនិងគេបង្គាប់ថ្លៃជំនូនឬអត់អ៊ី?

ខៈ ចាស! បង្គាប់!

កៈ អំ...ហើយកាលនឹងក្រុមគ្រួសាររបស់អ៊ីរស់នៅរយៈពេលបានប៉ុន្មានខែដែរ នៅប៉ុន្មានឆ្នាំហើយនៅក្នុងខេត្តនិង?

ខៈ នៅយូរដែរហើយប៉ុន្តែឥឡូវប្ដីរបស់ខ្ញុំគាត់បានខូច (ស្លាប់) បាត់ហើយ គាត់ស្លាប់តាំងពីកូននៅតូចទេ!

កៈ ចុះអ៊ីអត់មានបានចាំថានៅបានប៉ុន្មានឆ្នាំអីទេ?

ខៈ ខ្ញុំនៅបានប្រហែលបួនប្រាំឆ្នាំនឹងប្រហែលប្រាំ ប្រាំមួយឆ្នាំអីនិងគាត់ខូច(ស្លាប់) ទៅឥឡូវកូនធំគាត់ស្លាបតាំងពីកូននៅតូចគាត់ឈឺ!

កៈ ចាស!

ខៈ គាត់ឈឺមានជំងឺ!

កៈ អ៊ឺម!

ខៈ បងប្អូនប្រុងយកគាត់ទៅមើលហើយនិងប៉ុន្តែគាត់អត់ៗជា(ស្ដាប់អត់បាន ១១:២៧)!

កៈ អ៊ឹម!

កៈ មកមើលគាត់នៅកាល់ម៉ែត គាត់បានស្លាប់នៅកាល់ម៉ែតនិង!

កៈ អ៊ឹម...គាត់ខូច(ស្លាប់)យូរដែរហើយ!

ខៈ ចាស! គាត់ខូចប្រហែលប្រាំឆ្នាំ ប្រាំមួយឆ្នាំហើយគាត់ស្លាប់!

កៈ ចាស! ចុះអ៊ីសព្វថ្ងៃអ៊ីរស់នៅជាមួយនរណាគេខ្លះ?

ខៈ ខ្ញុំរស់នៅជាមួយបងនិងខ្ញុំគ្មានផ្ទះគ្មានសំបែងនៅទេ!

កៈ អ៊ីជួលផ្ទះគេនៅ!

ខ៖ ចាស! មុនដំបូងបងគាត់ជាអ្នកចេញថ្លៃផ្ទះអោយ!

ក៖ ផ្ទះនៅម្តុំណាដែរអ៊ីៗអាចប្រាប់ទីតាំងបានទេ?

ខ៖ នៅៗមុខពេទ្យពិភពក្រុងនិង នៅមុខពេទ្យពិភពក្រុងនិងសម្តេចឪពិភពក្រុង!

ក៖ ស្នាក់នៅមុខនិងតែម្តងអ៊ី?

ខ៖ ចាស! ខ្ញុំស្នាក់នៅហ្នឹង!

ក៖ គេហៅភូមិអីគេដែរអ៊ីនៅហ្នឹង?

ខ៖ នៅពីមុខពេទ្យពិភពក្រុងយើងនិង អូនឯងស្គាល់ទេ ពេទ្យពិភពក្រុងសម្តេងឪយើងនិង ពេទ្យពិភពក្រុងនិងអូនឯងស្គាល់ទេ?

ក៖ ចាស!

ខ៖ ចាសនិង! នៅពេទ្យនិងទៅសួរតែឈ្មោះ ទូច ច្រឹប និងទៅគេស្គាល់ហើយ!

ក៖ ចាស! ហើយអ៊ី...សាច់ញាតិរបស់អ៊ីមាននៅក្រៅប្រទេសឬអត់?

ខ៖ អត់ៗអត់មានបងប្អូននៅក្រៅប្រទេសផងខ្ញុំ មានតែនៅស្រុកភូមិរបស់យើងធម្មតានិងប្អូនរបស់ខ្ញុំគេមានប្តីហើយទៅរស់នៅខាងប្តីរបស់គេ បាត់ហើយនៅខ្ញុំអត់មានបងប្អូននៅរស់នៅក្រៅប្រទេសផង!

ក៖ ចាស! អ៊ីអាចប្រាប់ខ្ញុំបានអត់ពីដំបូងនឹងអ៊ីបានជួបស្វាមីរបស់អ៊ីនឹងនៅពេលណាដែរ?

ខ៖ ខ្ញុំជួបគាត់នៅពេលខ្ញុំធ្វើការមកធ្វើការទៅបានជួបគ្នា ធ្វើការនៅក្នុងហាងធ្វើការៗទៅបានប្តីរបស់ខ្ញុំគាត់ទៅឃើញគ្នាក៏ស្រោលាញ់គ្នាទៅស្រលាញ់គ្នា រហូតបានកូនមួយហ្នឹង!

ក៖ អ៎...ហើយចំពោះភាសាវិញអ៊ីចេះបានប៉ុន្មានភាសាដែរ?

ខ៖ ខ្ញុំបានរៀនតែភាសាខ្មែរនិងបានត្រឹមតែថ្នាក់ទីបីនឹងអត់ៗបានរៀន ផងយើងអត់មានលុយគ្រប់គ្រាន់សំរាប់រៀនណាស់ម្តាយខ្ញុំគាត់ឧស្សាហ៍ទៅចោលខ្ញុំ គាត់ឧស្សាហ៍ទៅបាត់ដំបងប៉ុន្មានឆ្នាំគាត់ទៅចោលខ្ញុំដល់អញ្ចឹងទៅខ្ញុំអត់បានរៀនគ្រប់គ្រាន់អ ត់បានរៀនដើររកការងារធ្វើអញ្ចឹងទៅយើងអត់បានរៀនណាស់កូនខ្ញុំតស៊ូអោយកូនខ្ញុំរៀនឥឡូ

វថ្នាក់ទីប្រាំពីរហើយកូនខ្ញុំថាឈប់រៀនហើយបើនៅរៀនទៀតម្ដាយអត់លុយអញ្ចឹងឈប់រៀនមកសុំគេធ្វើការបានធ្វើការងារលក់បាយអោយគេនិងណាស់!

ក៖ ចាស! អ៊ីហើយអ៊ី...អ៊ីចេះខ្មែរអីបានល្អទេទាំងការសរសេរចេះអានអីទេ?

ខ៖ ភាសាខ្មែរយើងនិងចេះធម្មតា!

ក៖ ការសរសេរប្រកបអានអីនិងបានទាំងអស់ហ្នឹង!

ខ៖ ចាស! ភាសាខ្មែរនឹងខ្ញុំចេះទាំងអស់និង!

ក៖ អ៊ីកាលនឹងបានរៀនត្រឹមថ្នាក់ទីប៉ុន្មាន?

ខ៖ បានរៀនត្រឹមថ្នាក់ថ្នាក់ទីបី មីអូនបានរៀនត្រឹមថ្នាក់ទីបីនិង (សើច)!

ក៖ អ៊ីរៀននៅសាលាណាដែរ?

ខ៖ រៀននៅសាលានៅស្រុករបស់ខ្ញុំរៀននៅសាលាវត្តចាស់!

ក៖ សាលាវត្តចាស់ហ៎អ៊ី?

ខ៖ ចាស! នៅស្រុកមុខកំពូលខេត្តកណ្ដាលរៀននៅសាលាវត្តចាស់!

ក៖ ចាស! អ៊ី...អ៊ីកាលនិងអ៊ីមានមិត្តភក្តិស្និទស្នាល់ឬអត់?

ខ៖ ចាស! មានប៉ុក៏ន្តែមិត្តភក្តិរបស់ខ្ញុំឥឡូវគេមានគ្រួសារអស់ហើយ (សើច)!

ក៖ ឥឡូវនៅរាប់អានគ្នាតើហីអ៊ី?

ខ៖ ចាស! នៅរាប់អានគ្នាធម្មតាៗនិង!

ក៖ ពួកគាត់មានឈ្មោះអ្វីដែរ?

ខ៖ ពួកម៉ាករបស់ខ្ញុំហ៎?

ក៖ ចាស!

ខ៖ គាត់មានឈ្មោះ ភាព អាភាព អារី និងពួកម៉ាករបស់ខ្ញុំ!

ក៖ មិត្តភក្តិជិតដិតជាងគេ!

ខ៖ ចាស! ឥឡូវគេមានគ្រួសារអស់ (សើច)!

កៈ តើអ៊ីមានការចងចាំរឿងអីគេខ្លះពីពួកគាត់?

ខៈ
អត់មានបានចងចាំអ្វីផងគ្រាន់តែថាយើងធ្លាប់ជាពួកម៉ាកនិងគ្នាទៅណាស់កាលពីមុនពួកម៉ាក់និងគ្នាធ្លាប់ដើរលេងជាមួយគ្នាធ្លាប់បានទៅរៀនជាមួយគ្នាឥឡូវគេមានគ្រួសាររបស់គេទៅបន្ទាប់មកទៀតគេរកស៊ីមកភ្នំពេញនិងបែកគ្នាគេដើររកការងារធ្វើទៅបានលុយចាយ
ខ្ញុំដើររកលុយបានបន្តិចបន្តួចអញ្ចឹងទៅឈឺរកបានមកឈឺឧស្សាហ៍ឈឺណាស់!

កៈ អ៊ីធ្លាប់ធ្វើស្រែអត់អ៊ី?

ខៈ ខ្ញុំធ្លាប់ធ្វើស្រែក៏ប៉ុន្តែម៉ែរបស់ខ្ញុំគាត់លក់អោយគេបាត់ហើយ ខ្ញុំធ្វើចំការ!

កៈ អញ្ចឹងគ្រួសាររបស់អ៊ីលើកមុនគាត់ជាកសិករ!

ខៈ ចាស!
ជាកសិករប៉ុន្តែដល់ពេលម៉ែខ្ញុំគាត់ឈឺណាស់ដល់នេះទៅគាត់លក់ដីលក់ចំការអោយគេទៅហើយបានកូនមានផ្ទះសំបែងនៅកូនស្រីមួយហ្នឹង!

កៈ អ៊ឹម...

ខៈ យាយវាថាអត់លក់ទេដីគាត់ថាទុកអោយចៅទុកអោយចៅគ្រាន់នៅពេលចៅបានកូនបានអីអញ្ចឹង
ហើយកាលនឹងដល់ពេលគាត់ឈឺក៏លក់ទៅដល់តែលក់ទៅខានបានចៅរស់នៅនឹងទៅ!

កៈ អ៊ឹម...

ខៈ ដល់ពេលអញ្ចឹងមកភ្នំពេញមករកការងារធ្វើ!

កៈ ចាសអ៊ី! អ៊ីហើយការងារអ្វីខ្លះដែលអ៊ីធ្លាប់ធ្វើនៅក្នុងជីវិតរបស់អ៊ី?

ខៈ
ខ្ញុំធ្វើចំការបេះសណ្តែកអោយគេអ្នកដែលគេមានចំការគេជួលយើងអោយទៅប្រមូលផងអោយគេ!

កៈ ធ្វើតែចំការនិងទេណ៎អ៊ីណ៎!

ខៈ ចាស!

កៈ ហើយនឹងដើររើសអេតចាយ!

ខៈ ក្នុងចំការគេនិងមានទាំងត្រឡាច អំពៅ ពោត អ្នកដាំនិងចំការនិងនៅស្រុកនៅរកាកោងនិងស្រុកចំការម៉ងនៅស្រុកក្នុងភូមិយើងចុះទៅឃើញសុទ្ធតែចំការពោតនិងគេដាំពីរមួយឆ្នាំពីរទៅបីដង!

កៈ ចាស!

ខៈ អឺ...គេមានដីណាស់ដល់ពេលយើងអត់មានយើងអត់បានធ្វើហ្នឹងគេទេ!

កៈ ចាស!

ខៈ កាលមុននឹងមានដីធ្វើជាមួយម្ដាយដល់ពេលម្ដាយលក់ទៅអត់បានធ្វើផង!

កៈ អ៊ំ...

ខៈ ម្ដាយរបស់ខ្ញុំគាត់ខ្វចអញ្ជឹងទៅក៏នាំកូនមកនៅភ្នំពេញពីរនោក់ម្ដាយកូនអត់មានផ្ទះសំបែងអោយកូននៅក៏ជួលផ្ទះគេនៅនឹងទៅ!

កៈ ចាស! អ៊ីតាំងពីនៅក្មេងរហូតមកដល់ឥឡូវជីវិតរបស់អ៊ីមានការផ្លាស់ប្ដូអីគេខ្លះដែរ?

ខៈ ផ្លាស់ប្ដូររបស់ខ្ញុំមានតែប៉ុណ្ណឹងខ្ញុំធ្លាក់ខ្លួនដើររើសអេតចាយនិង!

កៈ ចាស! ហើយអ៊ីចូលចិត្តមុខម្ហូបអីគេដែរ?

ខៈ ខ្ញុំចូលចិត្តហូបស្ងោរយើងហ្នឹង ហូបត្រីស្ងោរយើងនិងស្ងោរត្រីម៉ែខ្ញុំចូលចិត្តត្រីស្ងោរណាស់កាលគាត់នៅរស់ (សើច)!

កៈ សើច) មានតែមួយមុខនឹងទេអ៊ី?

ខៈ ចាស!

កៈ ចុះល្បែងវិញកាលនៅពីក្មេងអ៊ីចូលចិត្តលេងល្បែងអីគេដែរ?

ខៈ នៅពីរក្មេងខ្ញុំដូចជាអត់ចូលចិត្តលេងល្បែងផងឃើញគេលេងធម្មតាគេលេងស៊ីគូរមួយរយអីនិ

ងគេលេងៗធម្មតាដូចជាៗនេះអញ្ចឹងណាស់ដូចជាចូលឆ្នាំអញ្ចឹងទៅណាស់គេលេង ដល់យើងមើលគេលេងនឹងទៅ!

ក៖ ចាស! ហើយចុះចំរៀងវិញអ៊ីចូលចិត្តអីគេដែរ?

ខ៖ គេលេងគេមានទីពឹងដល់យើងអត់មានទីពឹងយើងអត់លេងដូចគេទេ (សើច)!

ក៖ ចាស!

ខ៖ ចាស!

ក៖ អញ្ចឹងការចងចាំបទចំរៀងវិញអ៊ីមានចាំបទចំរៀងអីគេតាំងពីក្មេងមកមានចាំបទចំរៀងអ្វីដែលចងចាំនិងដែលអ៊ីធ្លាប់ស្តាប់?

ខ៖ (សើច) អត់ចេះផង!

ក៖ អ៊ីចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ ចូលចិត្តធម្មតាប៉ុន្តែអត់ចេះចាប់អារម្មណ៍និងគេផង (សើច)!

ក៖ អ៊ីស្តាប់ហើយចោល (សើច)!

ខ៖ ដើរចេះតែស្តាប់ទៅគេស្តាប់អញ្ចឹងទៅពិរោះក៏ពិរោះទៅ!

ក៖ អ៎..អញ្ចឹងនៅក្នុងក្រុមគ្រួសាររបស់អ៊ីមានអ្នកណាចេះលេងឧបករណ៍ភ្លេងដែរឬទេ!

ខ៖ ឧបករណ៍ភ្លេងមានៗនៅប្អូនរបស់ខ្ញុំវាទៅមានប្តីទៅណាស់អត់មានអ្នកណាគនៅផង!

ក៖ ចាស! ចុះអត់មានអ្នកណាគេចេះខាងឧបករណ៍ភ្លេងទេនៅក្នុងគ្រួសាររបស់អ៊ីសមាជិកនៅក្នុងក្រុមគ្រួសាររបស់អីអត់មានទេហ៎?

ខ៖ អត់មានផងនិងរកអោយគេបង្រៀនលេងនៅណា!

ក៖ អញ្ចឹងផ្ទះរបស់អ៊ីមានលក្ខណៈយ៉ាងម៉េចដែរតាំងកាលពីក្មេងរហូតមមកដល់ឥឡូវ?

ខ៖ ខ្ញុំលក់អស់ហើយម្ដាយរបស់ខ្ញុំគាត់បានលក់ដីលក់ធ្លី (សើច) ហើយអឺ....ខ្ញុំកាលនិងមានគឺមានផ្ទះសំបែងអីត្រឹមត្រូវនិងណាស់ក៏ប៉ុន្តែគាត់លក់ដីលក់ផ្ទះអញ្ចឹងឯងទៅក៏កូនក៏អត់បាននៅដែរអឺ....ចៅអីហ្នឹង!

ក៖ អញ្ចឹងឥឡូវនិងមានន័យថាអត់មានផ្ទះនៅទេហ៎អ៊ី?

ខ៖ អត់ៗនៅភ្នំពេញនិងជួលផ្ទះគេនៅ បងគាត់ជួលផ្ទះនៅទៅខ្ញុំនៅជាមួយបងនិងទៅ!

ក៖ អ៊ឹម...ចាស! សោកស្ដាយមែនទែនហើយបងប្អូនរបស់អ៊ីម្នាក់ទៀតនិងគាត់នៅខាងខេត្តណាដែរ?

ខ៖ នៅខាងព្រៃវែងនិងគាត់នៅខាងប្ដីរបស់គាត់នៅផ្ទះខាងប្ដី!

ក៖ គាត់នៅតាមប្ដីរបស់គាត់?

ខ៖ ចាស! កូនគាត់ស្រីបានកូនស្រី!

ក៖ ហើយចុះម្ដាយរបស់អ៊ីគាត់ស្លាប់អស់អញ្ចឹងទៅអ៊ីក៏មកនៅទីនេះបែកគ្នាអស់ទៅ?

ខ៖ នៅបែកគ្នាប្អូនស្រីរបស់ខ្ញុំតាំងពីគេទៅមានប្ដីទៅ គេអត់មានមករស់ជាមួយខ្ញុំនឹងទេបងប្អូនរបស់ខ្ញុំហ្នឹង!

ក៖ ចាស! ចុះផ្ទះចាស់និងមានលក្ខណៈយ៉ាងម៉េចអ៊ីមានចាំទេ?

ខ៖ ផ្ទះចាស់និងឈើធ្វើពីឈើនិងលក់ម៉ែរបស់ខ្ញុំគាត់លក់ផ្ទះនឹងទៅ!

ក៖ ផ្ទះឈប់ហ្នឹងមានម៉ូតអីគេដែរ?

ក៖ ផ្ទះឈើម៉ូតធម្មតានិងគាត់ទិញយូរហើយកាលនិងគាត់រកបានដល់អញ្ចឹងទៅគាត់ទិញផ្ទះនិង!

ក៖ ចាស!

ខ៖ ទិញផ្ទះនឹងទិញហើយគាត់លក់វិញផ្ទះឈើយើងនិង!

ក៖ ហើយអឺ...អ៊ីសព្វថ្ងៃហ្នឹងអ៊ីកាន់សាសនាអ្វីដែរ?

ខ៖ ខ្ញុំអត់ដឹងដែរមិនបានកាន់សាសនាផងហ្នឹង!

ក៖ ខាងព្រះពុទ្ធសាសនាក៏អ៊ីអត់ដែលបានទៅវត្តដែរអញ្ចឹង?

ខ៖ ចាស! ខ្ញុំទៅៗពេលចូលឆ្នាំយើងនឹងទៅចូលឆ្នាំពេលរាប់បាទអីនឹងទៅខ្ញុំទៅរាប់បាទអីអស់នឹងធម្មតាទៅ!

ក៖ អ៊ឹម...ចាស! ហើយអ៊ី...អ៊ី តើអ៊ីចាប់ផ្តើមកាន់សាសនាព្រះពុទ្ធសាសនាតាំងពីពេលណាមក?

ខ៖ ខ្ញុំនៅកាលម៉ែរបស់ខ្ញុំនិងគាត់នៅដាំបាយដាំអីនិងទៅធ្វើម្ហូបយកទៅវត្តអញ្ចឹងទៅជូនកាលគាត់អោយដាំបាយទៅវត្តគាត់ទៅវត្តដែរ!

ក៖ ចាស!

ខ៖ ចាស! ទៅវត្តជុំគ្នា!

ក៖ ហើយចុះអ៊ី...សាសនាព្រះពុទ្ធសាសនានិងមានជះឥទ្ធិពលអ្វីខ្លះមកលើជីវិតរបស់អ៊ី?

ខ៖ អ៊ឹម...យើងទៅវត្តអញ្ចឹងទៅយើងដូសបាយដាក់ចង្ហាន់លោកប្រគេនលោកទៅណាស់យើងអុចធូបឧទ្ទិសដល់ជីដូនជីតារបស់យើងដែលគាត់ចែកឋានទៅដើម្បីអោយកាត់បានសុខបានទៅកាន់សុកតិភព!

ក៖ ចាស! ហើយចុះក្រុមគ្រួសាររបស់អ៊ីគាត់មានជំនឿដូចម្តេចដែរទៅព្រះពុទ្ធសាសនាដែរអ៊ី?

ខ៖ យើងមានជំនឿទៅលើយើងគិតទៅវត្តទៅវ៉ានិងនិងទៅណាស់ជួបជុំបងប្អូនជុំគ្នាទៅវត្តភ្ជុំនាំគ្នាទៅវត្តអ៊ឹម....ចូលឆ្នាំអីនិងយើងនាំគ្នាទៅវត្តធ្វើបាយសម្លរទៅវត្ត(សំលេងរំខាន)!

ក៖ ទៅតែវត្តអញ្ចឹងទៅអ៊ីហ៎ ទៅធ្វើបុណ្យធ្វើអី...

ខ៖ ចាស! ទៅធ្វើបុណ្យធម្មតាហើយពេលនេះទៅគាត់ទៅធ្វើបុណ្យអីធម្មតាហ្នឹង!

ក៖ ពេលគាត់ខូច(ស្លាប់) អីហ្នឹងទៅក៏ធ្វើបុណ្យទៅតាមព្រះពុទ្ធសានា!

ខ៖ ចាស!

ក៖ អ៊ីអាចប្រាប់ខ្ញុំបានអត់អំពីការលំបាករបស់អ៊ីនៅក្នុងជីវិតរបស់អ៊ីណាស់មានអីគេខ្លះដែលអ៊ី?

ខ៖
អឹម...សព្វថ្ងៃហ្នឹងដើររកបានតែមួយហូបៗជូនកាលបានព្រឹកអត់ល្ងាចពេលខ្លះបានល្ងាចអត់ព្រឹកអញ្ចឹងទៅគ្រាន់តែថាបើមិនប្រឹងទៅដើររកទេគឺអត់អីហូបនិងទៅ
កាលពីមុនម៉ែនៅម៉ែរកស៊ីចិញ្ចឹមៗឥឡូវដល់ពីរអត់ពីម្ដាយអញ្ចឹងទៅដើររកខ្លួនឯងដើររកបានទៅហូបទៅដើររកបានច្រើនហូបច្រើនដើររកបានតិចហូបតិច
បើរទេះខ្លួនឯងតែម្ដងយើងស្រួលដល់ពេលរបស់បងអញ្ចឹងទៅយើងពិបាកណាស់ពេលបងគាត់រកយើងអត់បានរកទេ!

ក៖ ត្រូវហើយអ៊ី!

ខ៖ ចាស!

ក៖
វាមានការលំបាកខ្លាំងណាស់ពីព្រោះជូនកាលឥឡូវនិងដូចជាថាដើររើសអត់សូវបានអញ្ចឹងទៅណាស់!

ខ៖ ចាស!
ទោះបីថាជារទេះរបស់ខ្លួនឯងតែម្ដងយើងដើររកក៏មួយថ្ងៃចេះតែរកបានប្រាំពាន់រៀលមួយម៉ឺនរៀលយើងចេះតែដើររកទៅណាស់
រកបានរបស់យើងប៉ុន្តែនេះជារបស់បងដល់ពេលអញ្ចឹងយើងចង់រកបងគាត់រកដៃរអញ្ចឹងពិបាកបើងមានរបស់ខ្លួនឯងតែម្ដងវាស្រួល!

ក៖ បងៗរបស់អ៊ីតែម្ដងឬជាបងប្អូនជីដូនមួយតើហី (មានសំលេងរំខានពីខាក្រៅ)!

ខ៖ បងប្អូនជីដូនមួយនៅនិងស្រុកនឹងមិនមែនបងប្អូនបង្កើតទេជាបងប្អូនជីដូនមួយនិង!

ក៖ អ៎...ចុះបានជួបគ្នាសុំគ្នាអញ្ចឹងទៅ!

ខ៖ ចាស!
ពេលគេរវល់អញ្ចឹងទៅយើងរកទៅដល់ពេលគេទំនេរគេរករបស់គេវិញទៅយើងបានតែមួយភ្លែតនិង!

ក៖ ចាស! ហើយចុះរទេះនិងអ៊ីធ្វើខ្លួនឯងឬយ៉ាងម៉េច?

ខ៖ រទេះនឹងអត់ទេគាត់ទិញគេអឺ...ដប់បីម៉ឺនរៀល!

ក៖ អ!

ខ៖ រទេះនឹងមានតំលៃបីដណ្តាប់ម៉ឺនរៀល (១៣ម៉ឺនរៀល) ចាស ទិញពីគែ យើងទិញពីគេឧបមាថារទេះនិងប្រាំដន្តប់ម៉ឺនរៀល (១៥ម៉ឺនរៀល) អញ្ចឹងទៅយើងតថ្លៃគេសល់ត្រឹមតែបីដណ្តាប់ម៉ឺនរៀល (១៣ម៉ឺនរៀល) នឹងទៅបានគាត់រកនិងដល់ពេលគាត់ទំនេរសុំគាត់រកទៅដល់ពេលគាត់រវល់ទៅ ដល់គាត់រវល់សុំគាត់រកទៅចាំដល់ពេលគាត់ទំនេរយកអោយគាត់វិញទៅ!

ក៖ ចាស! ចាស!

ខ៖ យើងចេះតែដើររទៅ!

ក៖ អ៊ីៗមានដែរមានបទពិសោធន៍ល្អៗអត់នៅក្នុងជីវិតរបស់អ៊ី?

ខ៖ ចាស! ខ្ញុំមានតែប៉ុណ្ណឹង!

ក៖ ចាស! ចុះបទពិសោធន៍ល្អៗដែលធ្វើអោយអ៊ីសប្បាយចិត្តមានដែរឬទេអ៊ី?

ខ៖ ដូចថាមានតែប៉ុណ្ណឹងជីវិតរបស់ខ្ញុំមានតែប៉ុណ្ណឹង!

ក៖ អ៊ឹម...អត់អ្វីដែលធ្វើអោយអ៊ីសប្បាយចិត្តទេហ៎អ៊ី?

ខ៖ ចាស!

ក៖ ដូចជាកូនដូចជាក្រុមគ្រួសារអ៊ីដូចជាកូនអីអញ្ចឹងណាស់?

ខ៖ អត់មានផងគ្មានអីសប្បាយចិត្តប្អូនរបស់ខ្ញុំគេទៅមានប្តីគេទៅអត់មានមកទេគេរវល់នឹងការងាររបស់គេខំប្រឹងតែធ្វើការគេហ្នឹង!

ក៖ ចាសអ៊ី! ជាចុងក្រោយ តើអ៊ីមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើរទៅដល់អ្នកដែលបានស្តាប់ជាពិសេសកូនចៅរបស់អ៊ីជំនាន់ក្រោយទៀត?

ខ៖ ចាស! ខ្ញុំសូមអោយគេចេះគិតចេះគូកុំអោយដូចៗខ្ញុំទៀតពិបាកអញ្ចឹងទៀតណាស់ពិបាកណាស់ម្តាយអត់មានចេះគិតកូនអញ្ចឹងទៅណាស់ដល់ពេលគាត់ខូច(ស្លាប់)ទៅគាត់ខូច(ស្លាប់)តែខ្លួន

ទៅគាត់អត់មានទុកដីទុកធ្លីអោយកូនចៅរស់នៅដល់គាត់អត់មានគិតគូកូនអត់មានទុកដីទុកអីអោយអញ្ចឹងធ្វើអោយយើងពិបាក
មានការពិបាកអញ្ចឹងទៅណាស់មានកូនស្រីតែមួយតស៊ូដល់មកភ្នំពេញនិងមករកកការងារធ្វើអញ្ចឹងវាពិបាក ដល់គេថាបានចូលធ្វើការហើយបានចូលពីរថ្ងៃបីថ្ងៃហើយបានខ្ញុំមក!

ក៖ អឺម...មានពាក្យអ្វីបន្ថែមទៀតទេអ៊ី!

ខ៖ ចាស! មានតែប៉ុណ្ណឹងទេខ្ញុំអត់មានអ្វីទៀតទេ(សើច)!

ក៖ ចាស! អញ្ចឹងអ៊ីជាចុងក្រោយអ៊ីធ្វើការអនុញ្ញាតដើម្បីអោយខ្ញុំធ្វើការដាក់យករូបរបស់អ៊ីនិងសំលេងរបស់អ៊ីដាក់ចូលទៅក្នុង Website របស់ខាងសាលាដែរឬទេ?

ខ៖ ចាស! ចាស!

ក៖ ចាស! អញ្ចឹងអរគុណច្រើនក្នុងថ្ងៃនិងដែលអ៊ីបានចំណាយពេលវេលាក្នុងការសម្ភាស!

ខ៖ ចាស!

ក៖ ហើយអញ្ចឹងខ្ញុំក៏សូមជូនពរអោយអ៊ីក៏ដូចជាក្រុមគ្រួសាររបស់អ៊ីទាំងអស់មានសុភមង្គលទាំងអស់គ្នា!

ខ៖ អឹម!

ក៖ ដើម្បីអោយអ៊ីមានសេចក្ដីសុខនៅក្នុងក្រុមគ្រួសាណាស់អ៊ីណាស់នៅក្នុងឆ្នាំថ្មីនិង!

ខ៖ ចាស!

ក៖ អរគុណច្រើនអ៊ី!